CITY OF LONG BEACH PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ៦ ខែឧសភាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ហាងតូចៗនិងសកម្មភាពលំហែកាយក្រៅផ្ទះមួយចំនួននឹងបើកដំណើរការឡើងវិញដោយមានការដាក់កម្រិតខ្លះនៅឡុងប៊ិច

ទីក្រុងឡុងប៊ិចរដ្ឋកាលីហ្វ័រញ៉ា – ថ្ងៃនេះទីក្រុងឡុងប៊ិចបានប្រកាសថាហាងតូចៗ ទីលានវាយកូនហ្គោល និងផ្លូវលំសាធារណៈនឹងបើកដំណើរការឡើងវិញដោយមានការដាក់កម្រិតខ្លះនៅថ្ងៃសុក្រទី ៨ ខែឧសភា។ ឱកាសលំហែកាយបន្ថែមនឹងបើកនៅថ្ងៃច័ន្ទទី ១១ ខែឧសភា។

លោកអភិបាលក្រុង Robert Garcia មានប្រសាសន៍ថា "ការសំរេចចិត្តរបស់យើងក្នុងការបើកដំណើរការឡើងវិញគឺផ្អែកលើការណែនាំដែលល្អបំផុតពីទីប្រឹក្សាសុខភាពសាធារណៈនិងទិន្នន័យដែលបង្ហាញពីស្ថិរភាពនៃចំនួនអ្នកសម្រាកនៅមន្ទីរពេទ្យនិងចំណុះដែលបានបង្កើននៅមន្ទីរពេទ្យរបស់យើង។ យើងសង្ឃឹមថាប្រជាជននឹងរីករាយជាមួយការកម្សាន្តបន្ថែមហើយនេះនឹងផ្តល់នូវការធូរស្បើយខ្លះដល់អាជីវកម្មខ្នាតតូចរបស់យើង។"

ទីក្រុងឡុងប៊ិចនៅតែបន្តមានករណីឆ្លងនិងអ្នកស្លាប់ដោយជំងឺកូវីដ-១៩តិចជាងខោនធី Los Angeles ។ ទីក្រុងឡុងប៊ិចមានចំណុះមន្ទីរពេទ្យគ្រប់គ្រាន់រីឯគ្រែអ្នកជម្ងឺប្រមាណជា ៥០ ភាគរយនៅទំនេរជារៀងរាល់ថ្ងៃ។ ទីក្រុងក៏មានប្រដាប់ជំនួយដកដង្ហើមច្រើនជាង ២២៥ ម៉ាស៊ីនហើយនៅគ្រប់ពេល ៧០ ភាគរយនៃម៉ាស៊ីនជំនួយដកដង្ហើមទាំងនេះនៅតែមានសម្រាប់ប្រើប្រាស់ជាបន្ទាន់។ កត្តាទាំងនេះបន្ថែម

ពីលើការធ្វើតេស្តទូលំទូលាយនឹងអនុញ្ញាតឱ្យហាងតូចៗនិងកន្លែងកម្សាន្តបន្ថែមមួយចំនួនបើកនៅថ្ងៃខាងមុខ។

ការផ្លាស់ប្តូរនឹងត្រូវបានត្រួតពិនិត្យយ៉ាងជិតដល់ហើយការឃ្លាតឆ្ងាយពីគ្នានៅតែជាកង្វល់ចំបង។

ចាប់ពីថ្ងៃទី ៨ ខែឧសភាឆ្នាំ ២០២០ ដោយមានពិធីសារអនាម័យនិងរក្សាចម្ងាយឆ្ងាយខាងរាងកាយឱ្យបានត្រឹមត្រូវមុនពេលប្រតិបត្តិការ៖

- អាជីវកម្មខាងក្រោមអាចបើកសម្រាប់ការមកយកតាមដងផ្លូវឬដឹកជញ្ជូនដល់គេហដ្ឋានតែប៉ុណ្ណោះ។ អាជីវកម្មដែលលក់:
    - ផ្កា
    - ប្រដាប់ក្មេងលេង
    - តន្ត្រី
    - សៀវភៅ
    - សម្លៀកបំពាក់
    - ទំនិញកីឡា
- ទីលានវាយកូនហ្គោលអាចចាប់ផ្តើមដំណើរការ។ រទេះវាយកូនហ្គោលត្រូវបានអនុញ្ញាតិឱ្យប្រើប្រាស់បានដរាបណារត្រូវបានសម្អាតដោយប្រើថ្នាំបំបាត់មេរោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការប្រឆាំងនឹងជំងឺកូវីដ-១៩រវាងការប្រើប្រាស់។ ស្តង់ដែលលក់អាហារសម្រន់និងភោជនីយដ្ឋានដែលមានទីតាំងនៅទីលានវាយកូនហ្គោលអាចដំណើរការសម្រាប់ការយកចេញតែប៉ុណ្ណោះ។ (មិនអនុញ្ញាតឱ្យបើកហាងលក់សម្លៀកបំពាក់និងសម្ភារៈនៅទីលានវាយកូនហ្គោលទេ។)
- ផ្លូវសាធារណៈនិងផ្លូវលំសាធារណៈ (DeForest Wetlands, Nature Center និង Willow Springs) នឹងត្រូវបានបើកជូនសូមឱ្យតែបុគ្គលម្នាក់ៗចូលរួមក្នុងសកម្មភាពរក្សាចំងាយរាងកាយពីគ្នារួមទាំងការពាក់ស្បៃឬរបាំងមុខនៅពេលដើរក្បែរអ្នកដទៃ។ របាំងមុខមិនតម្រូវនៅពេលដែលធ្វើការហាត់ប្រាណដែលនៅឆ្ងាយពីអ្នកដទៃទេ។ (ចំណតរថយន្តនឹងត្រូវបានបើកដើម្បីសម្រួលដល់ការចូលទៅកាន់ផ្លូវលំតែប៉ុណ្ណោះ)។
- បន្ទប់តាំងលក់រថយន្តអាចបើកលក់បានដោយប្រកាន់ខ្ជាប់នូវការរក្សាចំងាយរាងកាយពីគ្នានិងអនុវត្តពិធីការទប់ស្កាត់ការឆ្លង។

សម្រាប់ព័ត៌មានឬការណែនាំបន្ថែមម្ចាស់អាជីវកម្មឬនិយោជិកអាចទូរស័ព្ទមកលេខ 562.570.4BIZ (4249).

ចាប់ពីថ្ងៃទី ១១ ខែឧសភាឆ្នាំ ២០២០ ទីតាំងដូចខាងក្រោមនឹងបើកជាសាធារណៈដោយមានវិធានការណ៍ទាក់ទងនឹងការរក្សាចំងាយរាងកាយពីគ្នាដែត្រូវបានប្រកាន់ខ្ជាប់យ៉ាងតឹងរឹង៖

- កន្លែងលេងតិនីសដរាបណាមានពិធីសាររអនាម័យត្រឹមត្រូវនិងមានការរក្សាចម្ងាយរាងកាយដែលត្រូវបានអនុវត្តមុនពេលបើក
- កីឡាបាញ់ធ្នូ
- កីឡាវាយកូនគោលឪស
- ផ្លូវជិះកង់និងផ្លូវថ្មើរជើងនៅតាមបណ្តោយឆ្នេរខ្សាច់
- ចំណតរថយន្តនៅឧទ្យាន (ឆ្នេរសមុទ្រនៅតែបិទក៏ដូចជាកន្លែងចតនៅតាមឆ្នេរផងដែរ)

នៅប៉ុន្មានថ្ងៃខាងមុខនេះបទបញ្ជាសុខភាពបន្ថែមនឹងត្រូវបានចេញដើម្បីផ្តល់នូវទិសដៅនិងការបញ្ជាក់បន្ថែមអំពីរបៀបដែលវិស័យនីមួយៗនឹងត្រូវបានអនុញ្ញាតឱ្យបើកដោយសុវត្ថិភាពដែលស្របនឹងបទបញ្ជា "រក្សាសុវត្ថិភាពដោយនៅផ្ទះ"។

**សារអំពីឧទ្យាននៃទីក្រុងឡុងប៊ិចនៅថ្ងៃទិវាមាតា**

ទោះបីជាកន្លែងកីឡានិងឆ្នេរសមុទ្រនៃទីក្រុងត្រូវបានបិទចាប់តាំងពីចុងខែមីនាក៏ដោយឧទ្យានបានបើកសម្រាប់ការប្រើប្រាស់អកម្មដូចជាការដើរនិងជិះកង់។ ដោយសារតែទិវាមាតាជាធម្មតាទាក់ទាញការជួបជុំធំៗនៅឧទ្យានសាធារណៈមន្ត្រីទីក្រុងចង់រំឭកភ្ញៀវមកលេងថានៅថ្ងៃអាទិត្យទី ១០ ខែឧសភាឧទ្យាននឹងបើកសម្រាប់តែការប្រើប្រាស់អកម្មប៉ុណ្ណោះ។ ការប្រមូលផ្តុំនិងការដើរលេងកំសាន្តនឹងបរិភោគអាហារមិនត្រូវបានអនុញ្ញាតនៅក្នុងឧទ្យានឬចំណតរថយន្តឡើយ។

សកម្មភាពនេះត្រូវបានបង្កើតឡើងដោយមន្ត្រីសុខាភិបាលទីក្រុងគឺវេជ្ជបណ្ឌិត Anissa Davis និងយោងទៅតាម អំណាចបន្ទាន់ (Emergency Powers) ដែលផ្តល់ទៅឱ្យអ្នកគ្រប់គ្រងក្រុងតាមរយៈការប្រកាសអាសន្នក្នុងតំបន់ (Proclamation of Local Emergency)។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺកូវីដ-១៩រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើប្រពន្ធ័ហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

###